# អំពើហិង្សាពីដៃគូនៅសហគមន៍ផ្ទះជួលនៅភ្នំពេញ

## ការរកឃើញពីការសិក្សាស្រាវជ្រាវដោយ អង្គការក្លាហាន អង្គការភីន និង អង្គការអសក ខែកុម្ភៈ ឆ្នាំ២០១៩

### សលាកបត្រព័ត៌មាន ២/៤

## តើអ្នកបានដឹងអំពីករណីអំពើហិង្សាដែលកើតឡើងនៅក្នុងបន្ទប់ជួលក្នុងតំបន់នេះដែរឬទេ?




- មតិជាងមួយភាគបីបានបង្ហាញថាពួកគេផ្ទាល់ខ្លួនបានឃើញឬដឹងពីហេតុការណ៍ហិង្សាយេនឌ័រដែលបានកើតឡើងនៅក្នុងបន្ទប់ជួលក្នុងតំបន់របស់ពួកគេ។
- ថ្វីត្បិតតែមានមតិច្រើនបានលើកឡើងថាអំពើហិង្សាក្នុងគ្រួសារកំពុងតែថយចុះ ប៉ុន្តែជាក់ស្តែង អំពើហិង្សាក្នុងគ្រួសារនៅតែបន្តមាននៅក្នុងសហគមន៍មួយចំនួន។
- ការឆ្លើយតបមួយចំនួនធំបានលើកឡើងថាជនល្មើសស្ថិតនៅក្រោមឥទ្ធិពលនៃជាតិអាល់កុលនិង/ឬថ្នាំញៀន
- អំណាចមិនស្មើគ្នារវាងបុរសនិងស្ត្រី: មតិយ៉ាងច្រើនបានលើកឡើងថាអំពើហិង្សាក្នុងគ្រួសារជាវិធីសាស្ត្រដែលបុរសប្រើដើម្បីដាក់កំហិតលើដៃគូរបស់ខ្លួន: "ជាធម្មតាប្តីនឹងវាយប្រពន្ធនៅពេលដែលគាត់សុំលុយពីប្រពន្ធដើម្បីទិញស្រា ហើយនាងមិនអោយ" (បុគ្គលិកអង្គការក្រៅរដ្ឋាភិបាលនៅចាក់អង្រែលើ)។ ការច្រណែននិងកំហឹងក៏បានបង្ហាញនៅក្នុងចម្លើយមួយចំនួនផងដែរ

> "ស្វាមីម្នាក់បានប្រព្រឹត្តអំពើហិង្សាលើប្រពន្ធរបស់គាត់ ហើយបន្ទាប់មកប៉ូលីសត្រូវបានបញ្ជូនទៅបញ្ឈប់អំពើហឹង្សា។ ប៉ុន្មានថ្ងៃក្រោយមក នាងបានទៅស្នើអោយប៉ូលីសដោះលែងប្តីរបស់នាងអោយចេញពីគុកវិញ ដោយសារប្តីរបស់នាងជាអ្នករកលុយដើម្បីផ្គត់ផ្គង់គ្រួសាទាំងមូល ហេតុដូចនេះក្មេងៗមិនបានទៅរៀនទេ។"
>
> មន្ត្រីប៉ូលីសនៅតំបន់ចាក់អង្រែលើ

## តើអំពើហឹង្សាក្នុងគ្រួសារកំពុងតែថយចុះមែនទេ ?




អ្នកឆ្លើយតបភាគច្រើន ទាំងក្នុងការស្ទង់មតិនិងសម្ភាសន៍បានប្រាប់ថាពួកគេមានអារម្មណ៍ថាអំពើហឹង្សាក្នុងគ្រួសារមានការថយចុះនៅក្នុងសហគមន៍របស់ពួកគេ។

> "[អំពើហិង្សាក្នុងគ្រួសារ] គឺជាផ្នែកមួយនៃរឿងរ៉ាវផ្ទាល់ខ្លួនរបស់ខ្ញុំ - ស្វាមីខ្ញុំនិងខ្ញុំធ្លាប់មានជម្លោះជាមួយគ្នា។ ហើយគាត់បានវាយនិងបន្ទោសខ្ញុំដោយសារតែគាត់ប្រើប្រាស់គ្រឿងញៀននៅពេលនោះ។ គាត់មិនដែលយកចិត្តទុកដាក់ចំពោះក្មេងៗទេ - គាត់តែងតែខឹងរាល់អ្វីដែលខ្ញុំបាននិយាយ។"
>
> ស្ត្រីម្នាក់បានលើកឡើងនៅក្នុងការប្រជុំពិភាក្សាក្រុមនៅតំបន់ជើងឯក

## "តើអ្នកគិតថាអ្នកណាជាជនល្មើសចម្បងក្នុងអំពើហិង្សាលើស្ត្រីនៅក្នុងតំបន់នេះ ?"




*ការសិក្សានេះមានការស្ទង់មតិចំនួន 167 គ្រួសារការពិភាក្សាក្រុមចំនួន 6 និងការសម្ភាសអ្នកផ្តល់ព័ត៌មានសំខាន់ៗចំនួន 20 ។ សម្រាប់វិធីសាស្ត្រពេញលេញនិងការរកឃើញ អ្នកអាចរករបាយការណ៍តាមអ៊ីនធឺណែត www.klahaan.org/publications

ក្លាហាន klahaan brave
PEOPLE IN NEED CZECH REPUBLIC
UPWD
UNITED NATIONS HUMAN RIGHTS OFFICE OF THE HIGH COMMISSIONER Cambodia
EUROPEAN UNION